**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ...៤៧២...សហវ.[illegible]

រាជធានីភ្នំពេញ, ថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ ២០១១

**ជម្រាបជូន**
**ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក**
**នៃអគ្គនាយកដ្ឋានរតនាគារជាតិ**

**កម្មវត្ថុ:** ករណីសំណើសុំបុរេប្រទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» ជូននាយកដ្ឋានវិស្វកម្ម នៃ ក្រសួងធនធានទឹកនិងឧតុនិយម សម្រាប់ការងារស្តារប្រឡាយ និងសាងសង់សំណង់សិល្បការ លើ ប្រឡាយរងព្រៃខ្លុង ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ ។

**យោង:** - ចំណារដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០៤ ខែ មករា ឆ្នាំ ២០១១ លើលិខិតលេខ ៧៩១២ សហវ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១០ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- លិខិតលេខ ០៧៩ ធទឧ ចុះថ្ងៃទី ១២ ខែ មករា ឆ្នាំ ២០១១ របស់ក្រសួងធនធានទឹកនិងឧតុនិយម ។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុនិងយោងខាងលើ សូមជម្រាបឯកឧត្តមប្រតិភូជ្រាបថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រេចអនុញ្ញាតឲ្យក្រសួងធនធានទឹកនិងឧតុនិយម បុរេប្រទានថវិកាជំពូក ២១ «គម្រោងវិនិយោគផ្ទាល់» ចំនួន ១.១០០.០០០.០០០រៀល (មួយពាន់មួយរយលានរៀលគត់) ជូននាយកដ្ឋានវិស្វកម្ម នៃ ក្រសួងធនធាន ទឹកនិងឧតុនិយម សម្រាប់ការងារស្តារប្រឡាយ និងសាងសង់សំណង់សិល្បការលើប្រឡាយរង ព្រៃខ្លុង ស្ថិតក្នុងស្រុកគងពិសី ខេត្តកំពង់ស្ពឺ មានដូចខាងក្រោម:

-ស្តារប្រឡាយរងខ្សែទី ១ ប្រវែង ៦.២០០ម
-ស្តារប្រឡាយរងខ្សែទី ២ ប្រវែង ១.០០០ម
-សាងសង់សំណង់លូមូលដោះទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ១ ចំនួន ០៥កន្លែង
-សាងសង់សំណង់លូជ្រុងស្នាក់ទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ១ ចំនួន ០៦កន្លែង
-សាងសង់សំណង់លូជ្រុងឆ្លងកាត់ផ្លូវ លើប្រឡាយរងខ្សែទី ១ ចំនួន ០៤កន្លែង
-សាងសង់សំណង់លូមូលដោះទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ២ ចំនួន ០១កន្លែង
-សាងសង់សំណង់លូជ្រុងស្នាក់ទឹកទ្វារមួយ លើប្រឡាយរងខ្សែទី ២ ចំនួន ០៣កន្លែង

ខ្ទង់ប្រាក់បុរេប្រទាននេះ នឹងត្រូវទូទាត់ដោយឥណទានថវិការបស់ក្រសួងធនធានទឹកនិងឧតុនិយម ដោយអាណត្តិបើកប្រាក់ឲ្យបានទាន់ពេលវេលា ។

សូមឯកឧត្តមប្រតិភូទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**គាត ឈន់**

**ចម្លងជូន**
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី
- ក្រសួងធនធានទឹកនិងឧតុនិយម «ដើម្បីមុខការ»
- ឯកសារ-កាលប្បវត្តិ